

# ត្រូវការបន្ថែម ការការពារមែនទេ ?

## ធានារ៉ាប់រងបន្ថែមជាក្រុម សម្រាប់ការព្យាបាលដោយគ្រោះថ្នាក់ជាយថាហេតុ -

## ការសម្រាកព្យាបាលនៅមន្ទីរពេទ្យ

# I អត្ថប្រយោជន៍ និងបុព្វលាភធានារ៉ាប់រង

| អត្ថប្រយោជន៍ធានារ៉ាប់រង | | | គម្រោង Platinum | គម្រោង Gold | គម្រោង Sliver |
|---|---|---|---|---|---|
| ក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងជួបគ្រោះថ្នាក់ជាយថាហេតុក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបណ្តាលឲ្យកើតមានការសម្រាកព្យាបាលនៅមូលដ្ឋានសុខាភិបាលណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុននឹងទូទាត់សំណងធានារ៉ាប់រងដោយផ្អែកទៅតាមការកំណត់ដូចមានចែងក្នុងតារាងនេះ៖ | ចំណាយលើបន្ទប់សម្រាកធម្មតា | 100% | អតិបរមានៃសំណង | អតិបរមានៃសំណង | អតិបរមានៃសំណង |
| | ចំណាយលើបន្ទប់ ICU | 100% | | | |
| | ចំណាយព្យាបាលលើការវះកាត់ | 100% | | | |
| | ចំណាយលើថេយន្តសង្គ្រោះបន្ទាន់ | 100% | | | |
| | ចំណាយលើថ្លៃថ្នាំ ដែលប្រើប្រាស់ក្នុងអំឡុងពេលធ្វើរោគវិនិច្ឆ័យ(រួមបញ្ចូលទាំងថ្លៃចំណាយលើការពិគ្រោះជំងឺក្រៅក្នុងរយៈពេល៧២ម៉ោងមុនចូលសម្រាកនៅមន្ទីរពេទ្យ) | 100% | | | |
| | ចំណាយលើការស្កេន X-ray, ECG, ការពិនិត្យដោយប្រើប្រាស់ឧបករណ៍ផ្សេងៗ និងការប្រើប្រាស់បន្ទប់ពិសោធន៍ (រួមបញ្ចូលទាំងថ្លៃចំណាយលើការពិគ្រោះជំងឺក្រៅក្នុងរយៈពេល៧២ម៉ោងមុនចូលសម្រាកនៅមន្ទីរពេទ្យ) | 90% | $5,000 | $3,000 | $2,000 |
| | ចំណាយលើថ្លៃថ្នាំ ដែលមិនពាក់ព័ន្ធនឹងការធ្វើរោគវិនិច្ឆ័យ | 85% | | | |
| | ចំណាយលើការព្យាបាលផ្សេងៗ | 80% | | | |

បុព្វលាភធានារ៉ាប់រងនឹងត្រូវកំណត់ផ្អែកទៅតាមមុខរបរ ប្រភេទការងារ អាយុ ប្រវត្តិស្ថានភាពសុខភាពរបស់អ្នកត្រូវបានធានារ៉ាប់រង និងចំនួនមនុស្សដែលនឹងត្រូវធានា។

ចំណាំ៖ ខិតបណ្ណផ្សព្វផ្សាយនេះគឺជាការពណ៌នាដោយសង្ខេប។ សម្រាប់ព័ត៌មានលម្អិត សូមអាន ខ និងលក្ខខណ្ឌធានារ៉ាប់រង។
ក្នុងករណីដែលកើតមានភាពមិនស៊ីចង្វាក់គ្នា ត្រូវយក ខ និងលក្ខខណ្ឌធានារ៉ាប់រងជាគោល។

# I ករណីមិនធានា

១.ក្រុមហ៊ុនធានារ៉ាប់រងនឹងមិនមានទំនួលខុសត្រូវក្នុងការផ្តល់សំណងធានារ៉ាប់រងឡើយ ប្រសិនបើនៅពេលដាក់ពាក្យស្នើសុំ អ្នកស្នើសុំធានារ៉ាប់រងមិនបានជូនដំណឹងពិតដល់ក្រុមហ៊ុន មានការលាក់បាំងអំពីស្ថានភាពសុខភាពដែលមានសភាពមិនល្អរបស់អ្នកត្រូវបានធានារ៉ាប់រងដូចករណីរៀបរាប់ខាងក្រោម៖

(១)អ្នកត្រូវបានធានារ៉ាប់រងបានធ្វើរោគវិនិច្ឆ័យរកឃើញថាមានជំងឺរ៉ាំរ៉ៃមួយ ឬច្រើនប្រភេទ ឬជំងឺស្រួចស្រាវ ឬជំងឺសតិអារម្មណ៍

(២)អ្នកត្រូវបានធានារ៉ាប់រងមានពិការភាព ឬមុខងារនៃភ្នែក ឬត្រចៀក ឬចលនារាងកាយមានភាពមិនប្រក្រតី

(៣)អ្នកត្រូវបានធានារ៉ាប់រងប្រកបមុខរបរមានហានិភ័យខ្ពស់ដែលក្រុមហ៊ុនមិនអាចធានាបាន

(៤)អាយុពិតប្រាកដរបស់អ្នកត្រូវបានធានារ៉ាប់រងនៅពេលដែលកិច្ចសន្យាបានបង្កើត មិនសមស្របតាមអាយុសម្រាប់ដាក់ពាក្យស្នើសុំដូចបានចែងក្រោម ខ និងលក្ខខណ្ឌក្នុងកិច្ចសន្យាធានារ៉ាប់រង។

២.ព្រឹត្តិការណ៍ផ្សេងៗនៃ "ករណីមិនធានា" ដែលបានចែងក្នុងផលិតផលធានារ៉ាប់រងមូលដ្ឋាន("គម្រោងការពារខ្លួនជាក្រុម")។

៣.ចំណាយសម្រាប់ការព្យាបាលដែលបណ្តាលមកពីជំងឺ។